# មេរៀនប្រចាំថ្ងៃ

## មុខវិជ្ជា៖សីលធម៌ពលរដ្ឋវិជ្ជា

**ថ្នាក់ទី១២**

## ជំពូកទី១៖តម្លៃមនុស្ស

## មេរៀនទី៣៖ល្បិចទូទៅនៃគំនិត

បង្រៀនដោយអ្នកគ្រូ ៖ ហុក ធីតា

មកពីវិទ្យាល័យព្រះស៊ីសុវត្ថិ សាលារៀនជំនាន់ថ្មី

# រំលឹកមេរៀន

ខ. ឡានមានកម្លាំងម៉ាស៊ីន ធំជាងម៉ូតូ, ឡានមានទំហំធំជាងម៉ូតូ សំគាល់អំពី៖

- បញ្ញាតិ
- វិនិច្ឆ័យ ☑
- វិចារ
- អនុមានញ៉ែក

# រំលឹកមេរៀន

អ្នកក្រតែងជួបការលំបាក ‘បុរសA’ ជាអ្នកក្រ ដូចនេះ ”បុរសA” តែងជួប ការលំបាក គឺជា៖

- បញ្ញាតិ
- វិនិច្ឆ័យ
- វិចារ ☑
- អនុមានញៀក

ដូចម្ដេចដែល
ហៅថាអនុមាន
ញែក?

អនុមានញែក ជាវិចារ
មួយបែបដែលញែកសេចក្ដី
សន្និដ្ឋានចេញពីគោល
ការណ៍ទូទៅ(រួម) ទៅរក
វិបាក ឬចេញពីរួមទៅរក
ភាពដោយឡែក ។





# ដូចម្ដេចដែលហៅថា វិភាគ? តើវិភាគមានប៉ុន្មាន? អ្វីខ្លះ?



# មាតិកា

៤.អម្ភន្តរញ្ញាណ

៥.ទំនាក់ទំនងរវាងអព្ភន្តរញ្ញាណនិងវិចារ

៦.ភាពខុសគ្នារវាងអម្ភន្តរញ្ញាណ និងវិចារ

# ដូចម្ដេចដែលហៅថាអព្ភន្តរញាណ? អព្ភន្តរញាណមានអ្វីខ្លះ?

អព្ភន្តរញាណ  គឺជាពុទ្ធិដែលបានមកពីការចង់បានផ្ទាល់និងភ្លាមៗដោយមានលក្ខណៈជាចំណេះដឹងផ្ទាល់ភ្លាមៗ ជាវិចារណភាពគ្មានតិចនិច គ្មានវិធីទាក់ទងទៅនឹងមនុស្សម្នាក់ៗដែលជាប្រធានវិស័យភាពនោះឡើយ។ អព្ភន្តរញាណមាន៖

-អព្ភន្តរញាណចិត្តវិទ្យា ជាការដឹងគុណក្នុងចិត្តរបស់បុគ្គលម្នាក់ៗ (ម្ដាយឈឺ យើងខូចចិត្ត)

-អព្ភន្តរញាណឥន្ទ្រីយ៍ ជាចំណេះដឹងដែលទទួលបានតាមរយៈអង្គវិញ្ញាណ (ល្វីង ជូរ ចត់...)

-អព្ភន្តរញាណបញ្ញា  អាចឲ្យយើងចាប់បាននូវទំនាក់ទំនង  ហើយអាចឈានទៅរកការបង្កើតថ្មី (ឃើញសត្វហើរ ផុសគំនិតបង្កើតយន្តហោះ)

-អព្ភន្តរញាណបរមត្ថវិជ្ជា ឬអស្សិរបវិជ្ជា អាចឲ្យយើងចាប់បាននូវតថភាពមួយដែលជាខ្លឹមសារផងនិងជាអត្ថិភាពផង។

# តើអព្ភន្តរញ្ញាណ និង វិចារមានទំនាក់ទំនងគ្នាដូចម្តេច?

អព្ភន្តរញ្ញាណ និង វិចារមានទំនាក់ទំនងគ្នាដោយៈ

-អព្ភន្តរញ្ញាណជាអ្នកចាប់យកនូវរបកគំហើញឯវិចារជាអ្នកវិភាគលើរបកគំហើញនោះ ។

-អព្ភន្តរញ្ញាណជាអ្នកផ្តល់សម្ភារៈសំណង់ ឯវិចារជាអ្នកចម្រាញ់ការប្រើប្រាស់សម្ភារៈនោះ ។

-អព្ភន្តរញ្ញាណជាអ្នករកឃើញនូវទំនាក់ទំនង ឯវិចារជាអ្នកបង្ហាញនូវតម្លៃនៃទំនាក់ទំនងនោះ។

-អព្ភន្តរញ្ញាណមានភាពរហ័សពេកខ្វះហេតុផល ដូចនេះវាត្រូវការវិចារដែលមានភាពយឺតកម្រភ្លាំងភ្លាត់។

# តើអព្ភន្តរញ្ញាណ និងវិចារមានភាពខុសគ្នាដូចម្តេច?

❖ អព្ភន្តរញ្ញាណ

-ជាពុទ្ធិដំបូងបង្អស់របស់មនុស្ស

-ជាពុទ្ធិផ្ទាល់និងភ្លាមៗ

-អវិចារណភាព

-ជាពុទ្ធិបែបសំយោគ

-ជាពុទ្ធិគ្មានទំនាក់ទំនង គ្មានលំដាប់លំដោយ គ្មានគោលការណ៍

-មានលក្ខណៈជាប្រធានវិស័យភាព

❖ វិចារ

- ជាពុទ្ធិបន្ទាប់

-ជាពុទ្ធិប្រយោល

-ជាពុទ្ធិបែបវិភាគ

-ជាពុទ្ធិដែលផ្អែកលើការពិចារណាល្អិតល្អន់

-ជាពុទ្ធិដែលមានទំនាក់ទំនង មានលំដាប់ មានគោលការណ៍ច្បាស់លាស់

-មានលក្ខណៈជាវត្ថុវិស័យភាព

# ដូចម្ដេចដែលហៅថាពុទ្ធិ? តើពុទ្ធិមានប៉ុន្មាន? អ្វីខ្លះ?

ពុទ្ធិសំដៅលើចំណេះដឹងទូទៅរបស់មនុស្ស។

ពុទ្ធិមានបី គឺ៖

-ពុទ្ធិសាមញ្ញ ជាពុទ្ធិធម្មតា អ្នកផងអាចមានគ្រប់គ្នា កើតពីការឮតៗគ្នាមានភាពស្រពិចស្រពិល មិនច្បាស់លាស់ គ្មានលំដាប់ គ្មានការត្រួតពិនិត្យម៉ត់ចត់ ហើយច្រើនផ្អែកលើបទពិសោធន៍ដែលមានស្រាប់ ឧ.ផ្គរព្រុះមិនដែលខាំ។





# បំណកស្រាយបន្ត



-ពុទ្ធិស្បង់ (ពុទ្ធិវិទ្យាសាស្ត្រ) ជាពុទ្ធិដែលកើតពីការពិសោធន៍ ។ ឧ.ទឹកពុះនៅ ១០០ អង្សារ

-ពុទ្ធិទស្សនវិជ្ជា ជាពុទ្ធិដែលកើតពីការត្រិះរិះពិចារណា ជាពុទ្ធិសំយោគមានលក្ខណៈជ្រាលជ្រៅជាងពុទ្ធិសាមញ្ញ និងពុទ្ធិវិទ្យាសាស្ត្រ ឧ. ព្រះពុទ្ធ មានបន្ទូលថា មានរូបគឺមានទុក្ខ ។



# ពង្រឹងពុទ្ធិ

ចូរជ្រើសរើសចម្លើយត្រូវខុសក្នុងល្បះខាងក្រោម៖

ត្រូវ ១.ជាពុទ្ធិដំបូងបង្អស់របស់មនុស្ស គឺអព្ភន្តរញាណ

ត្រូវ ២.ជាពុទ្ធិដែលមានទំនាក់ទំនងមានលំដាប់មានគោលការណ៍ច្បាស់លាស់ គឺវិចារ

ខុស ៣.ពុទ្ធិសាមញ្ញជា (ពុទ្ធិវិទ្យាសាស្ត្រ) ជាពុទ្ធិដែលកើតពីការពិសោធន៍

ត្រូវ ៤.ពុទ្ធិទស្សនវិជ្ជា ជាពុទ្ធិដែលកើតពីការត្រិះរិះពិចារណា ជាពុទ្ធិសំយោគមានលក្ខណៈជ្រាលជ្រៅជាងពុទ្ធិសាមញ្ញ


សូមអរគុណ!


QUESTIONS?
COMMENTS?
CONCERNS?